**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ: ០៦៩/១៥ ក.អ.ជ.ប្រក

ថ្ងៃ ចន្ទ ៣ រោច ខែ ចេត្រ ឆ្នាំ មមី ព.ស.២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា គ.ស ២០១៥

# ប្រកាស
## ស្តីពី
## ការកែសម្រួលមន្ត្រីរាជការសម្រាប់បំពេញការងារនៅអង្គភាពអនុវត្តន៍គម្រោង កែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពី ការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤
- យោងប្រកាសលេខ ១៥៩/១៤ ក.អ.ជ.ប្រក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើត និងតែងតាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការសម្រាប់បំពេញការងារនៅក្នុងអង្គភាពគ្រប់គ្រង និងអង្គភាពអនុវត្តន៍គម្រោងកែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងមន្ត្រីរាជការសម្រាប់បំពេញការងារនៅអង្គភាពអនុវត្តន៍គម្រោងកែលម្អផ្លូវជនបទជំហានទី២ ដែលមានសមាសភាព ដូចខាងក្រោម៖



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

ក). ខេត្តសៀមរាប

| | | | |
|---|---|---|---|
| ១. | លោក **ស៊ីម រដ្ឋា** | ជាអ្នកសម្របសម្រួលគម្រោង | ជំនួសលោក **ហោង សុខអេង** ដែលត្រូវបានទទួលភារកិច្ចថ្មី។ |
| ២. | លោក **សន ស្រស់** | ជាមន្ត្រីសង្គម និងបរិស្ថាន | ជំនួសលោក **ស្រី ពលរដ្ឋ** |
| ៣. | លោក **ម៉ាច សុផារិទ្ធ** | ជាអ្នកបើកបរ | ជំនួសលោក **ចុឡាន់ សុទិដ្ឋា**។ |

ខ). ខេត្តបន្ទាយមានជ័យ

| | | | |
|---|---|---|---|
| ១. | លោក **ជា យុទ្ធារុណ** | ជាអ្នកសម្របសម្រួលគម្រោង | ជំនួសលោក **ខេង ញ៉ឹល** ដែលត្រូវបានទទួលភារកិច្ចថ្មី។ |

គ). ខេត្តបាត់ដំបង

| | | | |
|---|---|---|---|
| ១. | លោក **សុខ ចណ្ណារឿន** | ជាអ្នកសម្របសម្រួលគម្រោង | ជំនួសលោក **ស៊ីម រដ្ឋា** ដែលត្រូវបានទទួលភារកិច្ចថ្មី |
| ២. | លោក **សេង សុខុម** | ជាមន្ត្រីបច្ចេកទេស | ជំនួសលោក **ភាត់ វ៉ាទី** |
| ៣. | លោក **ភាត់ វ៉ាទី** | ជាមន្ត្រីសង្គម និងបរិស្ថាន | ជំនួសលោក **សេង ទិសិទ្ធ**។ |

**ប្រការ ២.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល**

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៣*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអភិវឌ្ឍន៍ជនបទ

ជា សុផារ៉ា



Download